## ខ្លឹមសារសង្ខេបសាលដីកាតុលាការកំពូលលេខ៣៩៥IV(២០២២) មនុស្សឃាដដោយចេតនា

**ពាក្យគន្លឹះ៖** មនុស្សឃាដដោយចេតនា, ការចូលរួមប្រព្រឹត្ត, សិទ្ធិទទួលបានសវនាការក្នុងពេលសមស្រប

### ១.អង្គហេតុនិងប្រវត្តិនីតិវិធី

កាលពីថ្ងៃទី៣ ខែតុលា ឆ្នាំ២០០៥ នៅក្នុងភូមិត្បូងដំរី ស្រុកខ្សាច់កណ្ដាល មានហេតុការណ៍សម្លាប់មនុស្សម្នាក់។ អង្គហេតុនេះ ត្រូវបានចោទជាបទមនុស្សឃាដដោយចេតនា តាមមាត្រា៣នៃច្បាប់ស្ដីពីស្ថានទម្ងន់នៃបទឧក្រិដ្ឋ លើបុគ្គលចំនួន៣រូប។ សាលាដំបូងខេត្តកណ្ដាល បានចេញសាលក្រមលេខ៣៥ឈ ខែកញ្ញាឆ្នាំ២០១៤ ផ្ដន្ទាទោសដាក់ពន្ធនាគារចំនួន១០ឆ្នាំម្នាក់ៗ និងចេញដីកាចាប់ខ្លួនជនទាំងបី។ ឆ្នាំ២០២០ សាលាដំបូងបានតម្កល់ទោស១០ឆ្នាំតាមសាលក្រមចំពោះមុខ ជនជាប់ចោទម្នាក់ **(ធីតា)** លេខ២២៤(ថ) ខែកុម្ភៈឆ្នាំ២០២០។ ធីតា បានប្ដឹងឧទ្ធរណ៍ត្រង់ចំណុចទាំងមូលនៃសេចក្ដីសម្រេច។ សាលាឧទ្ធរណ៍បានចេញសាលដីកាលេខ៣ក្រIVវន ខែមករា ឆ្នាំ២០២២ ដោយតម្កល់សាលក្រមលេខ២២៤ថ។ **ធីតា** បានប្ដឹងសាទុក្ខ ប្រឆាំងនឹងសាលដីកាទាំងមូល។ តំណាងមហាអយ្យការអមតុលាការកំពូល ស្នើឲ្យកុំពិចារណាលើបណ្ដឹងសាទុក្ខនេះ ដោយសារ ម្ចាស់បណ្ដឹងសាទុក្ខ មិនបានដាក់សារណាការពារបណ្ដឹងសាទុក្ខ។ មេធាវីការពារជនក្រីក្រ បានបញ្ជាក់ពីអវត្តមាននៃជនជាប់ចោទ នៅកន្លែងកើតហេតុ លទ្ធភាពនៃការស្លាប់នៃជនរងគ្រោះមានច្រើន (អាចស្រវឹងធ្លាក់ទឹកទន្លេ) មិនមានសាក្សីឃើញ និងចង្អុលបង្ហាញជនជាប់ចោទបានប្រព្រឹត្ត...នៅមានវិមតិសង្ស័យធ្ងន់ធ្ងរ។ ដើមបណ្ដឹងរដ្ឋប្បវេណី បានអះអាងថា ក្រោយកើតហេតុ **ធីតា** នៅក្នុងភូមិ មិនបានរត់គេចទៅណាទេ។ តុលាការកំពូលបានបើកសវនាការ និងចេញសាលដីកាលេខ៣៩៥ ខែកញ្ញា ឆ្នាំ២០២២។

### ២.សំអាងហេតុនិងសេចក្ដីសម្រេច

ក្រោយពីបានពិចារណារួច តុលាការកំពូលបានយល់ឃើញ ហើយដែលខ្លឹមសារសំខាន់មួយចំនួនគួរដកស្រង់ជូន៖ ការប្រកាសទោសលើជនជាប់ចោទឈ្មោះ**ធីតា** ពីបទមនុស្សឃាដដោយចេតនា ដោយសំអាងលើចម្លើយសាក្សីថា ក្រោយកើតហេតុ **ធីតា** បានគេចខ្លួន មិនមានមូលដ្ឋានគ្រប់គ្រាន់នៅឡើយ។ ដើមបណ្ដឹងរដ្ឋប្បវេណី បានអះអាងថា **ធីតា** មិនបានរត់គេចទេ។ *ភស្តុតាងកន្លែងកើតហេតុពុំបានរកឃើញវត្ថុតាងអ្វី ដែលមានទំនាក់ទំនងជាមួយជនជាប់ចោទឈ្មោះ **ធីតា** នោះទេ។ មិនមានភស្តុតាងផ្ទាល់ណាមួយអាចឲ្យតុលាការជឿជាក់បង្ហាញថា ជនជាប់ចោទឈ្មោះ **ធីតា** បានប្រព្រឹត្តអំពើមនុស្សឃាត ចូលរួមសម្លាប់...ទេ។*

**សម្រេចៈ** **២**.បដិសេធសាលដីកាលេខ១០៣...**៣**.បញ្ជូនសំណុំរឿង...ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជម្រះជាថ្មីឡើងវិញ។

## ៣.កំណត់សំគាល់

**១**. មកដល់ឆ្នាំសវនាការរបស់តុលាការកំពូល មានរយៈពេល១៧ឆ្នាំ។ តុលាការកំពូល បានសម្រេចបង្វិលទៅសាលាឧទ្ធរណ៍។ មកដល់ឆ្នាំ ខែកុម្ភៈ ឆ្នាំ ២០២៣ នេះ មិនទាន់ត្រូវបានជំនុំជម្រះជាថ្មីទេ។ **ធីតា** បានជាប់ក្នុងពន្ធនាគារចំនួនប្រហែល ៤ឆ្នាំ។

**២**. ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មិនបានចែងជាក់លាក់ ដាក់កម្រិតឲ្យធ្វើសវនាការឲ្យបានឆាប់ទេ។ កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ មាត្រា១៤(៣) តម្រូវឲ្យមានសវនាការក្នុងពេលសមស្រប ដែលរយៈពេលនេះចាប់គិតពីថ្ងៃស៊ើបអង្កេតរហូតដល់សាលក្រមឬសាលដីកាស្ថាពរ។ រយៈពេលយូរ ឬឆាប់ អាចនាំឲ្យបំពានមាត្រានេះ វាអាស្រ័យលើកាលៈទេសៈនៃសំណុំរឿងនីមួយៗ ក្នុងករណីខ្លះ ការយឺតយ៉ាវ មិនសមហេតុផលបណ្តាលមកពីទង្វើរបស់ជនជាប់ចោទ។ ការពន្យាសវនាការ អាចនាំឲ្យសាក្សីបាត់ការចងចាំ ភស្តុតាងអាចខូច ឬបាត់បង់...ជនជាប់ចោទខ្លួនឯងភ្លេចអស់នូវភស្តុតាង ដែលពិបាកក្នុងការការពារខ្លួន ការកាត់សេចក្តីក្នុងកាលៈទេសៈដូចនេះ អាចមិនយុត្តិធម៌។

**៣**. បុគ្គលមានសិទ្ធិសេរីភាព ហើយប្រសិនសិទ្ធិត្រូវបានបំពាន ដំណោះស្រាយ ដូចជាសំណងដ៏មានប្រសិទ្ធភាព ត្រូវផ្តល់ជូន (មាត្រា២.៣.កនៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ)។ អវតក ធ្លាប់ប្រកាសដករយៈពេលទោសដល់ **ឌុច** ជាសំណងចំពោះការឃុំខ្លួនដោយខុសច្បាប់ដោយតុលាការយោធា មុនឌុចត្រូវបានផ្ទេរទៅឃុំខ្លួនក្នុងមន្ទីរឃុំឃាំង អវតក (សេចក្តីសម្រេចដោះលែង E39/5 ទំ.២៦)។ មាត្រា១២៨ថ្មីនៃច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា ចែងថាតុលាការជាអ្នកធានាសិទ្ធិ ដូចនេះ គួរតែមានដំណោះស្រាយឬសំណង។